ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គិសនីកម្ពុជា
គណៈកម្មាធិការលទ្ធកម្ម
លេខ:.....261.....PEAC អ.ក

# សេចក្តីជូនដំណឹងលើកទី២
## ស្តីពី
## ឈ្នួលពលកម្មវិនិយោគពង្រីកខ្សែបណ្តាញអគ្គិសនីដើម្បីជួយកាត់រំលែកបន្ទុក S383 នៅសង្កាត់បឹងកេងកង៣ ខណ្ឌចំការមន រាជធានីភ្នំពេញ និង វិនិយោគខ្សែបណ្តាញអគ្គិសនីថ្មីដើម្បីកាត់រំលែកបន្ទុកនៅ P989 ដែលស្ថិតនៅផ្លូវបេតុង សង្កាត់ទួលសង្កែ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ ជូននាយកដ្ឋានអាជីវកម្មចែកចាយ

អគ្គិសនីកម្ពុជាសូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឲ្យបានជ្រាបថា:អគ្គិសនីកម្ពុជានឹងដាក់ឲ្យពិគ្រោះថ្លៃជាសាធារណៈ ដើម្បីជ្រើសរើសអ្នកទទួលការងារស្តីពីឈ្នួលពលកម្មវិនិយោគពង្រីកខ្សែបណ្តាញអគ្គិសនីដើម្បីជួយកាត់រំលែកបន្ទុក S383 នៅសង្កាត់បឹងកេងកង៣ ខណ្ឌចំការមន រាជធានីភ្នំពេញ និង វិនិយោគខ្សែបណ្តាញអគ្គិសនីថ្មីដើម្បីកាត់រំលែកបន្ទុកនៅ P989 ដែលស្ថិតនៅផ្លូវបេតុង សង្កាត់ទួលសង្កែ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ ជូននាយកដ្ឋានអាជីវកម្មចែកចាយ ។

អគ្គិសនីកម្ពុជាបានរៀបចំឯកសារសំរាប់ ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមពិគ្រោះថ្លៃ ។ ឯកសារពិគ្រោះថ្លៃមានដាក់លក់នៅអង្គភាពលទ្ធកម្មដែលមានអាសយដ្ឋាន៖ ផ្លូវព្រះយុគន្ធរ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ចាប់ពី ថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១៧ តទៅរៀងរាល់ម៉ោងធ្វើការ( ទូរស័ព្ទទំនាក់ទំនង៖ 023 6766007 និង Website:www.edc.com.kh)

ឯកសារពិគ្រោះថ្លៃដែលបានបំពេញរួចត្រូវប្រគល់ជូនអង្គភាពលទ្ធកម្ម យ៉ាងយូរបំផុតត្រឹមថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៧ វេលាម៉ោង ១១ : 00 នាទី។

ការបើកសំណើពិគ្រោះថ្លៃនឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្ម តាមអាសយដ្ឋានខាងលើ វេលាម៉ោង ១៥:៣០ នាទី ថ្ងៃទី ១៦ ខែកុម្ភៈ ឆ្នាំ២០១៧។

ក្រុមហ៊ុន/សហគ្រាស ដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬ មានប្រភពតែមួយអាចដាក់សំណើពិគ្រោះថ្លៃបានតែមួយគត់។

ក្រុមហ៊ុន/សហគ្រាស ដែលមានបំណងចូលរួមពិគ្រោះថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ដើម្បីទិញ ឯកសារពិគ្រោះថ្លៃ និងសាកសួរព័ត៌មានដែលទាក់ទងនឹងការដេញថ្លៃនេះ។

រាជធានីភ្នំពេញ, ថ្ងៃទី 08 ខែ 02 ឆ្នាំ២០១៧
ប្រធានគណៈកម្មាធិការលទ្ធកម្ម

ឆឹង_អ៊ឹង

ចម្លងជូន៖
-អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
-អង្គភាពប្រឆាំងអំពើពុករលួយ